## បុគ្គល-ទលនឹង-បុគ្គល

ជួយអ្នកចូលរួមទាំងឡាយ ឲ្យមានការចម្រើនល្អតលាស់ទៅរកការបម្រើការងារតាមរយៈគម្រោងផែនការឯកត្តជនពិសេស, ការបង្រៀនជំនាញការ, ហើយនិងព័ត៌មាននិងការបញ្ជូនសេវាកម្ម ។

## សេវាត្រៀមប្រកបវិជ្ជាជីវៈ

សេវាកម្មដែលផ្តល់ការរៀបចំនីតិជនសម្រាប់ចូលបម្រើការងារ ។

## សេវាផ្តលនីតិសម្បទាសម្រាបជនអសមត្ថភាព

ជំនួយក្នុងការរៀនសូត្រ, ការបង្កើន ឬការរក្សាជំនាញការផ្នែកសង្គមកិច្ចនិងការសម្របខ្លួនទៅតាមស្ថានភាពចាំបាច់សម្រាបការរសនៅក្នុងសហគមន៍ ។ សេវាកម្មដែលផ្តោតលើសុខភាព និងសុវត្ថិភាព, អំណាចនិងជំរើសផ្ទាល់ខ្លួន, សមត្ថភាពនិងការពឹងពាកលើខ្លួនឯង, និងការកសាងទំនាក់ទំនងជាវិជ្ជមាន ។

## ការថែទាំជំនួសជាបណ្តោះអាសន្នម្តងម្កាល

ជំនួយសម្រាប់រយៈពេលខ្លីដលបុគ្គល ដែលមើលថែទាំមនុស្សណាម្នាក់ ដែលមានជម្ងឺពិការផ្នែកអភិវឌ្ឍន៍នីតិសម្បទា ។

## សេវាគិលានុបដ្ឋាកិច្ចជំនាញ

សេវាគិលានុបដ្ឋាកិច្ច ឬសេវាតំណាងគិលានុបដ្ឋាយិកា មានដំណើរការបន្តជានិរន្តរ, ម្តងម្កាល, ឬពាក់កណ្តាលមោង ដែលផ្តលការបម្រើដោយគិលានុបដ្ឋាយិកាមានវិញ្ញាបនបត្រណាម្នាក ។

## បរិក្ខាឯកទេសវេជ្ជសាស្ត្រ និងគ្រឿងផ្គតផ្គង

បរិក្ខាវេជ្ជសាស្ត្រចាំបាច់ និងគ្រឿងផ្គតផ្គង់ផ្សេងៗ ដែលមិនមានការដាក់ឲ្យដំណើការក្រោមផែនការជំនួយ Medicaid របស់រដ្ឋ (Medicaid State Plan) ទេ ។

## សេវាកម្មផ្នែកឯកទេសវិកលចរិក

សេវាវិកលចរិកផ្តោតលើសេចក្តីត្រូវការនានារបស់បុគ្គល ដែលមានជម្ងឺពិការផ្នែកអភិវឌ្ឍន៍នីតិសម្បទា ។

## កម្មវិធីពិគ្រោះយោបល និងហ្វឹកហ្វឺនបុគ្គលិក/គ្រួសារ

ការហ្វឹកហ្វឺន និងការពិគ្រោះយោបលប្រកបដោយវិជ្ជាជីវៈភាពចំពោះគ្រួសារ និងអ្នកផ្តលការបម្រើសេវាកម្មផ្ទាល់ ដើម្បីតម្រូវតាមសេចក្តីត្រូវការនានារបស់ជនណាម្នាកឲ្យបានកាន់តែល្អប្រសើរឡើង ។

## ការគាំទ្រការងារ

ការគាំទ្រជាបុគ្គល និងជាក្រុមឲ្យបានល្អិតល្អន និងជានិច្ចនិរន្តរ ដើម្បីជួយទ្រទ្រង់ការងារ ។

## ការធ្វើដំណើរដឹកជញ្ជូន

ការសងប្រាក់សោហ៊ុយដល់អ្នកផ្តលការបម្រើឯកត្តជនសម្រាបការធ្វើដំណើរដឹកជញ្ជូន ដែលមិនទាក់ទងនឹងវេជ្ជសាស្ត្រ ត្រូវគេតម្រូវឲ្យមានសេវាអនុគ្រោះ ដូចបានបញ្ជាកនៅក្នុងផែនការឧបត្ថម្ភឯកត្តជន ។

***សេវាបន្ថែមមានបម្រើការតែនៅក្រោមកម្មវិធីជំនួយអនុគ្រោះ CIIBS ប៉ុណ្ណោះ ៖***

## បច្ចេកវិជ្ជាជំនួយការ

ផលិតផលដែលត្រូវបានប្រើប្រាស់ ដើម្បីបង្កើន ឬរក្សាសមត្ថភាពនៃការបញ្ចេញឥន្ទ្រិយរបស់បុគ្គលណាម្នាក់ និងសេវានានា ដើម្បីជួយដល់បុគ្គលនិងអ្នកថែទាំរបស់បុគ្គលរូបនោះក្នុងការជ្រើសរើស, អភិរក្ស, និងប្រើប្រាស់បច្ចេកវិជ្ជានោះ។

## សំលៀកបំពាក់ឯកទេសកម្ម

សំលៀកបំពាក់មិនតឹងចង្អៀត ដែលឃើតរីកប្រែប្រួលទៅតាមសេចក្តីត្រូវការនីមួយៗរបស់បុគ្គល ស្របតាមពិការភាពរបស់គាត់។

## អាហារជីវជាតិឯកទេសកម្ម

អាហារដែលត្រូវបានរៀបចំពិសេស ឬប្រភេទអាហារជាក់ លាក់នានាដែលជនរូបនោះត្រូវការដើម្បីទ្រទ្រង់រាងកាយនៅផ្ទះគ្រួសារ និងសេវាវាយតម្លៃ, សេវាអាហារជីវជាតិ, និងសេវាត្រួតពិនិត្យពីអ្នកជំនាញផ្នែកអាហារូបត្ថម្ភ។

## បរិក្ខារនិងគ្រឿងផ្គត់ផ្គង់វិធីព្យាបាលរោគ

បរិក្ខារនិងគ្រឿងផ្គត់ផ្គង់នានាដែលត្រូវបានបញ្ចូលទៅក្នុងផែនការឧបត្ថម្ភឥរិយាបថវិជ្ជមាន ឬផែនការព្យាបាលរោគដទៃៗទៀតដែលចាំបាច់ដើម្បីធ្វើឲ្យវិធីព្យាបាល ឬអន្តរាគមន៍បានសម្រេច។

## ការកែប្រែយានយន្ត

ការកែប្រែយានយន្តដើម្បីសម្រួលទៅតាមសេចក្តីត្រូវការដ៏ពិសេសរបស់ជនរូបនោះ, ការធ្វើសមាហរណ័កម្មពេញលេញទៅក្នុងសហគមន៍, និងការធ្វើឲ្យប្រាកដថាសុខភាព, សុខុមាលភាព, និងសុវត្ថិភាពរបស់បុគ្គលរូបនោះ និង/ឬបណ្តាសមាជិកនានារបស់គ្រួសារជួបនឹងសុខដុម។

---

ក្រសួង DSHS មិនរើសអើងចំពោះ និងផ្តល់សិទ្ធិស្មើភាពដល់មនុស្សទាំងអស់ក្នុងការប្រើប្រាស់កម្មវិធី និងសេវាកម្មនានារបស់វា ដោយមិនគិតអំពីជាតិសាសន៍, ពណ៌សម្បុរ, ភេទ, សាសនា, គោលជំនឿ, ស្ថានភាពអាពាហ៍ពិពាហ៍, ជាតិកំណើត, ចំណូលចិត្ត/ការស្រឡាញ់ផ្លូវភេទ, អាយុ, ស្ថានភាពអតីតយុទ្ធជន ឬវត្តមានពិការភាពខាងរាងកាយ, ខាងវិញ្ញាណ, ឬខាងសតិឡើយ។




**តំបន់ 1**
1611 W. Indiana Ave.
Spokane, WA 99205-4221
Phone (509) 329-2900
1 (800) 462-0624

**តំបន់ 2**
3700 Fruitvale Blvd.
Suite 200
Yakima, WA 98909-2500
Phone (509) 225-4620
1 (800) 822-7840

**តំបន់ 3**
840 N. Broadway
Bldg. A., Suite 100
Everett, WA 98201-1288
Phone (425) 339-4833
1 (800) 788-2053

**តំបន់ 4**
1700 E. Cherry St. # 200
Seattle, WA 98122
Phone (206) 568- 5700
1 (800) 314-3296

**តំបន់ 5**
1305 Tacoma Ave. S.
Suite 300
Tacoma, WA 98402
Phone (253) 404-6500
1 (800) 248-0949

**តំបន់ 6**
Point Plaza East
Bldg. 2, 3rd Floor
6860 Capitol Blvd. SE
Olympia, WA 98504-5315
Phone (360) 725-4250
1 (800) 339-8227

សម្រាប់ពិស្តារបន្ថែម,
សូមមើលគេហទំព័រ DDD ៖

**www.dshs.wa.gov/ddd**



នាយកដ្ឋាន
អភិវឌ្ឍន៍
ពិការភាព

# សេវាអនុគ្រោះផ្អែកលើមូលដ្ឋានគេហដ្ឋាននិងសហគមន៍

## ព័ត៌មានមូលដ្ឋានស្តីពីលក្ខណសម្បត្តិ, លទ្ធភាព, និងសេវាកម្ម

Washington State
Department of Social & Health Services

ADSA Aging & Disability Services Administration

DSHS 22-605 CA (Rev. 8/09)

## សេចក្ដីសង្ខេបស្ដីពីកម្មវិធីជំនួយអនុគ្រោះ

Medicaid របស់រដ្ឋ និងការឧបត្ថម្ភផ្សេងៗទៀតមិនមានការទ្រទ្រង់គ្រប់គ្រាន ។ នាយកដ្ឋានអភិវឌ្ឍន៍ពិការភាព (Division of Developmental Disabilities – DDD) ផ្ដល់សេវាបម្រើអតិថិជនក្រោមកម្មវិធីអនុគ្រោះប្រាំប្រភេទគឺ ៖ *Basic (មូលដ្ឋាន), Basic Plus (មូលដ្ឋានបូក), Children's Intensive In-home Behavioral Support (ឧបត្ថម្ភឥរិយាបថតាមផ្ទះលម្អិតរបស់កុមារ – CIIBS), Core (សេវាស្នូល), និង Community Protection (ការពារសហគមន៍)* – ដែលសេវានីមួយៗមានលក្ខខណ្ឌកម្រិតជាក់លាក់ចំពោះបរិមាណកម្រៃ, បរិមាណសេវា, និងចំនួនអ្នកចុះឈ្មោះ។ សម្រាប់ព័ត៌មានពិស្តារបន្ថែម, សូមមើលក្រដាសអង្គហេតុផែនការនៅលើទំព័រអ៊ីនធឺណិត DDD ឬសូមទាក់ទងជាមួយ DDD តែម្តង ។

## លក្ខណៈវិនិច្ឆ័យលើលក្ខណសម្បត្តិអនុគ្រោះ

- បុគ្គលគឺជាអតិថិជនរបស់ DDD ។
- បុគ្គលមានជម្ងឺពិការអ្វីមួយស្របតាមលក្ខណៈវិនិច្ឆ័យ ដែលបានបង្កើតឡើងនៅក្នុងច្បាប់ Social Security Act (ច្បាប់សន្តិសុខសង្គម) ។
- បុគ្គលត្រូវតែមានប្រាក់ចំណូល ដែលអាចរាប់បាន មិនលើសពី 300% តាមស្តង់ដារជំនួយសហព័ន្ធផ្នែកកម្មវិធី SSI និងធនធានដែលអាចរាប់បាន មិនលើសពី $2,000 ឬមិននៅក្នុងកម្មវិធីថែទាំសុខភាពសម្រាប់កម្មករមានពិការភាព (Health Care for Workers with Disabilities – HWD) ។ នៅក្នុងករណីដែលបុគ្គលជាកុមារ, ប្រាក់ចំណូល និងធនធានរបស់ឪពុកម្តាយមិនត្រូវបានរាប់បញ្ចូលទេ នៅពេលគេកំណត់មើលលក្ខណសម្បត្តិរបស់កូនសម្រាប់ការអនុគ្រោះនោះ ។ ក្នុងករណីដែលបុគ្គលជានីតិជនកំពុងរស់នៅជាមួយប្តីឬប្រពន្ធ, ប្រាក់ចំណូល និងធនធានរបស់ប្តីឬប្រពន្ធក៏មិនត្រូវបានគេរាប់បញ្ចូលដែរ ។
- បុគ្គលត្រូវការកម្រិតនៃការថែទាំ ដែលត្រូវផ្តល់ផ្តល់ក្នុងមន្ទីរថែទាំជាមធ្យមសម្រាប់ជនវិកលសតិ (Intermediate Care Facility for the Mentally Retarded–ICF/MR) ។
- ផែនការគាំទ្រឯកត្តជនដែលគេបានរៀបចំ ត្រូវបង្ហាញពីរបៀបដែលសេចក្តីត្រូវការផ្នែកសុខភាព, សុវត្ថិភាព, និងទីតិសម្បទារបស់បុគ្គលអាចជួបតាមសេចក្តីតម្រូវក្នុងសហគមន៍ជាមួយសេវាអនុគ្រោះប្រចាំខែ ។
- បុគ្គលបានយល់ព្រមទទួលសេវាកម្មផ្អែកលើមូលដ្ឋានគេហដ្ឋាន និងសហគមន៍ទុកជាជម្រើសផ្សេងមួយ ជំនួសសេវាកម្មស្ថាប័នក្នុង ICF/MR ។
- សម្រាប់តែសេវា CIIBS មួយប៉ុណ្ណោះ, អ្នកចូលរួមត្រូវតែ៖
  - មានអយុចាប់ពី 8 រហូតដល់ 17 ឆ្នាំ ដើម្បីអាចទទួលបានការចុះឈ្មោះដំបូង (ធ្លាប់បម្រើជូនរហូតដល់អាយុ 20 ឆ្នាំ);
  - ត្រូវតែពីដំបូងបានវាយតម្លៃមើលថាមានការប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ ឬធ្ងន់ធ្ងរ ពីការដាក់ឲ្យគេជួយចិញ្ចឹមនៅក្រៅផ្ទះ ដោយព្រោះមានឥរិយាបថមិនធម្មតា; ហើយ
  - ត្រូវតែរស់នៅជាមួយគ្រួសារណា ដែលយល់ព្រមចូលរួមក្នុងកម្មវិធីនេះ។

## សិទ្ធិចេញចូលទទួលការអនុគ្រោះ

អ្នកអាចស្នើសុំឲ្យគេចុះឈ្មោះលើការអនុគ្រោះមួយ ឬក៏ចុះឈ្មោះក្នុងការអនុគ្រោះមួយផ្សេងទៀតនៅពេលណាក៏បានដែរ ។ អ្នកអាចធ្វើកិច្ចការនោះដោយទាក់ទងជាមួយនាយកគ្រប់គ្រងសំណុំរឿងរបស់អ្នក ឬដោយការប្រើលិខិតដាក់ពាក្យសុំលើប្រព័ន្ធអ៊ិនធឺរណិត ។

បើបច្ចុប្បន្ននេះអ្នកមិនទាន់បានចុះឈ្មោះទទួលការអនុគ្រោះនៅឡើយ, ការជួបតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការអនុគ្រោះមិនធានាថា អ្នកមានសិទ្ធិចេញចូលទទួលសេវាអនុគ្រោះទេ ។ ការអនុគ្រោះនិមួយៗមានការកម្រិតសម្រាប់ចំនួនមនុស្ស ដែលអាចត្រូវគេបម្រើក្នុងឆ្នាំអនុគ្រោះ។ បន្ថែមលើនេះ, DDD មានអំណាចដាកកម្រិតក្នុងការចុះឈ្មោះមនុស្សក្នុងកម្មវិធីអនុគ្រោះទាំងប៉ុន្មានដោយផ្អែកលើការមានមូលនិធិសម្រាប់អ្នកចូលរួមក្នុងការអនុគ្រោះថ្មីៗទៀត ។

## សិទ្ធិសវនាការរដ្ឋបាល

វាជាកាសំខានណាស ដែលអ្នកត្រូវដឹងថា អ្នកមានសិទ្ធិទទួលសវនាការរដ្ឋបាល(សវនាការយុត្តធម៌) បើអ្នកមានការជំទាស់ទៅនឹងបណ្ដឹងណាមួយ ដូចតទៅនេះ ៖

**ការកំណតលក្ខណសម្បត្តិ DDD ៖**

- បើអ្នកត្រូវគេបដិសេធលក្ខណសម្បត្តិជំនួយ; ឬ
- បើលក្ខណសម្បត្តិជំនួយរបស់អ្នកត្រូវបានគេបញ្ឈប; ឬ
- បើមានការពន្យារពេលមិនសមហេតុផលណាមួយក្នុងការពិនិត្យលិខិតដាក់ពាក្យសុំរបស់អ្នកសម្រាបលក្ខណសម្បត្តិជំនួយ ។

**វិធានការនៃសេវាកម្ម ៖**

- បើអ្នកមិនយលស្របជាមួយប្រភេទ ឬចំនួននៃសេវាកម្ម ដែលគេអនុញ្ញាតឲ្យអ្នកទទួល; ឬ
- បើអ្នកត្រូវគេបដិសេធមិនឲ្យទទួលសេវាកម្ម ដែលអ្នកបានសុំ; ឬ
- បើអ្នកត្រូវគេបញ្ជូនឲ្យទៅរសនៅក្នុងលំនៅដ្ឋានណាមួយផ្សេងទៀត, ដែលមិនមែនជាជម្រើសរបស់អ្នក; ឬ
- បើសេវាកម្មរបសអ្នកត្រូវគេកាតបន្ថយ ឬបញ្ចប; ឬ
- បើ DDD ធ្វើការសម្រេចថា សេវាកម្មដែលមានលើការអនុគ្រោះបច្ចុប្បន្នរបស់អ្នកអាចជួបតាមសេចក្តីត្រូវការផ្នែកសុខភាព និងសុខុមាលភាពរបស់អ្នក ហើយអ្នកមិនយលស្រប ។

**ការមិនព្រម ឬការបដិសេធន៍ចំពោះសេចក្ដីស្នើសុំ ៖**

- ការបដិសេធន៍ចំពោះសេចក្ដីស្នើសុំរបស់អ្នកក្នុងការទទួលសេវា ICF/MR ជំនួយសេវាអនុគ្រោះ;
- ការមិនព្រមធ្វើតាមសេចក្ដីស្នើសុំរបសអ្នក កុំឲ្យផ្ញើសេចក្ដីជូនដំណឹងទៅឲ្យជនណាម្នាក់ផ្សេងទៀត; ឬ
- ការមិនព្រមពិនិត្យមើលការអនុគ្រោះ ដែលអ្នកស្នើសុំ ។ បើអ្នកមានសំណួរ, សូមទូរស័ព្ទទាក់ទងនាយកគ្រប់គ្រងធនធាន សំណុំរឿង DDD របសអ្នកសម្រាបស្វែងយលព័ត៌មានពិស្តារ បន្ថែម ។

## ការឲ្យនិយមន័យនៃសេវាអនុគ្រោះ

សេវាកម្មនានាដែលអ្នកទទួលសេវាអនុគ្រោះម្នាក់ៗទទួល គឺត្រូវផ្អែកលើសេចក្ដីត្រូវការផ្នែកសុខភាព និងសុខុមាលភាព ដែលគេសម្គាល់ឃើញព្រមជាមួយនឹងកំណត់ហេតុក្នុងផែនការឧបត្ថមឯកត្តជន (Individual Support Plan) ឯទៀតៗ ។

### គេហដ្ឋានមានអាជ្ញាប័ណ្ណសំរាបថែទាំនីតិជន (AFH)

គេហដ្ឋានគ្រួសារធម្មតាមួយ ដែលមានជនណាម្នាក់ត្រូវបានគេផ្តលអាជ្ញាប័ណ្ណ ឲ្យផ្តតផ្តងការថែទាំផ្ទាលខ្លួន, ការថែទាំពិសេស, ទីស្នាក់អាស្រ័យ ហើយនិងបាយទឹកសម្រាប់មនុស្សច្រើនជាងម្នាក តែតិចជាង 6 នាក់ ។

### មន្ទីរថែទាំនីតិជនអសមត្ថភាព (ARC)

គេហដ្ឋានមានអាហាររួបត្ថម្ភសម្រាប់នីតិជនដែលគ្មានជាបទំនាកទំនងនឹងគ្នា ចាប់ពី 7 នាក់ឡើងទៅ, ដោយមានការផ្តលជំនួយសម្រាបការបង្កសកម្មភាពរស់នៅជាប្រចាំថ្ងៃ ។

### ការគ្រប់គ្រងឥរិយាបថ និងការពិគ្រោះយោបល

កម្មវិធីដែលបានរៀបចំឡើង ដើម្បីទ្រទ្រង់ឯកត្តជនក្នុងការសម្តែងឥរិយាបថតាមមធ្យោបាយផ្សេងៗ ដែលធ្វើឲ្យប្រសើរឡើងដលការបញ្ចូលទៅក្នុងសហគមន៍, រួមមានទាំងការជួយធ្វើអន្តរាគមន៍ដោយផ្ទាល ដើម្បីកាត់បន្ថយឥរិយាបថរឹងរូសនានា ដែលជួយសម្រួលសមត្ថភាពរបស់សាមីជនក្នុងការរក្សាជីវភាពក្នុងសហគមន៍ ។

### សិទ្ធិចេញចូលទទួលសេវាសហគមន៍

សេវាកម្មដែលគេផ្តល់នៅក្នុងសហគមន៍សម្រាបជនដែលមានអាយុចាបពី 62 ឆ្នាំឡើងទៅ ដើម្បីបង្កើន ឬរក្សាប្រសិទ្ធភាព, សមាហរណភាព, និងជំនាញការអនុវត្តន៍ ឬសតិបញ្ញារបស់សាមីជន ប្រយោជន៍នឹងជួយសាមីជនឲ្យមានការចម្រើនលូតលាសទៅរកការប្រកបការងារ ឬការចូលនិវត្តន៍ ។

### ការណែនាំផ្អែកសហគមន៍

សេវាកម្មសម្រាប់រយៈពេលខ្លី ដែលបង្កើនលទ្ធភាពទទួលការឧបត្ថម្ភសហគមន៍តាមរបៀបក្រៅផ្លូវការ ។

### ជំនួយក្នុងភាពអាសន្ន

ការកើនឡើងជាបណ្តោះអាសន្នក្នុងកម្រិតនៃប្រាក់ជំនួយប្រចាំឆ្នាំ ដូចមានការបញ្ជាក់ក្នុងជំនួយអនុគ្រោះមូលដ្ឋាន (Basic Waiver) និងជំនួយអនុគ្រោះមូលដ្ឋានបូក (Basic Plus Waiver) នៅពេលណាគេតម្រូវឲ្យមានសេវាអនុគ្រោះនានាបន្ថែមទៀត ។

### ការសម្របខ្លួនទៅតាមសិទ្ធិចេញចូលក្នុងបរិយាការ

ការសម្របកាយទៅតាមគេហដ្ឋាន ដែលតម្រូវឲ្យសាមីជនអាចបន្តការរស់នៅក្នុងសហគមន៍ ។

### ការពង្រីកសេវាផែនការរបសរដ្ឋ

សេវាកម្មនានាដែលពង្រីកហួសពីកម្រិតនៃផែនការជំនួយ Medicaid របសរដ្ឋសម្រាប់ការព្យាបាលផ្នែកអាជីព, រាងកាយ, ការនិយាយ, និង ភាសា ។

### សេវាផ្តលស្ថេរកម្មនៃសុខភាពផ្លូវចិត្ត

សេវាជួយបណ្តាជន ដែលកំពុងឆ្លងកាត់វិបត្តិផ្នែកសុខភាពផ្លូវចិត្ត ។

### ការថែទាំផ្ទាលខ្លួន

វិធានការនៃជំនួយសម្រាប់សកម្មភាពរសនៅប្រចាំថ្ងៃ ។